១- វិស័យអភិវឌ្ឍន៍ធនធានមនុស្ស គឺ :

នៅពេលគណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ចបានទទួលការគាំទ្រពីប្រជាជនអោយកាន់អំណាច យើងចាំបាច់អនុវត្តន៍គោលការណ៏ដូចតទៅ :

-ចាត់អោយមានការរៀនសូត្រគ្រប់គ្នានូវអក្សរសាស្រ្ត ។

-ចាត់អោយមានអាហារថ្ងៃត្រង់សំរាប់សិស្សបថមសិក្សា ។

-ចាត់អោយសិស្សរៀនពេញម៉ោង ព្រឹក ល្ងាច ។

-ចាត់សាលារៀនជូនប្រជាជន ដើម្បីអោយកូនចៅបានចូលរៀនសូត្រត្រឹមត្រូវ ទៅតាមសង្គមត្រូវការ ។

-ចាត់មិនអោយមានគ្រូបង្រៀនយកប្រាក់ពីសិស្ស ទោះនៅក្នុងករណីណាក៏ដោយ ។

២- អភិវឌ្ឍវិស័យកសិឧស្សាហកម្ម

-រៀបចំប្រព័ន្ធធារាសាស្រ្ត ទឹកស្រោចស្រប់ ជូនពលរដ្ឋគ្រប់ទីកន្លែង។

-រៀបចំទីផ្សារជូនពលរដ្ឋ ដោយរដ្ឋជាអ្នកកំណត់ និងធានាតម្លៃកសិផលជូនពលរដ្ឋ ជំរុញអោយមានសមាមាត្រតម្លៃជូនពលរដ្ឋ។

-រៀបចំមុខជំនាញកសិកម្មជូនពលរដ្ឋ ដោយផ្តល់ទុនកម្ចីជូននិងធានាតម្លៃជាវិជ្ជមានជូនពលរដ្ឋ នូវតម្លៃកសិផលកសិកម្ម ។

-រៀបចំអោយមានឧស្សាហកម្មខ្នាតតូចនិងមធ្យម ដើម្បីទទួលទិញកសិផលពីពលរដ្ឋ ដោយធានាតម្លៃជាក់លាក់ជូន។

-រៀបចំផ្តល់រង្វាន់ជូនពលរដ្ឋដែលបើករោងឧស្សាហកម្មកែច្នៃ និងធានាតម្លៃជាវិជ្ជមានជូនពលរដ្ឋ។

៣- អភិវឌ្ឍន៏វិស័យទេសចរណ៏ ,

-ចាត់តំបន់ទេសចរណ៏ វប្បធម៏ដែលមាន និងកំពុងរុករក អោយទៅជាប្រយោជន៍ជាតិ និងចាត់អោយពលរដ្ឋមានការងារធ្វើតាមរយ:ទេសចរណ៏ ដោយផលិតរបស់អនុស្សាវរីយ៏លក់ជូនភ្ញៀវទេស ចរណ៏ ។ល។

-ចាត់តំបន់ទេសចរណ៏ធម្មជាតិ សំរាប់ទទួលភ្ញៀវទេសចរណ៏ ផ្តល់ការងារអោយពលរដ្ឋជុំវិញតំបន់មានការងារធ្វើតាមរយ:វិស័យទេសចរណ៏ ។

-ចាត់តំបន់ទេសចរណ៏កែច្នៃ អោយក្លាយទៅជាទេសចរណ៏សម័យ ផ្តល់ការងារជូនពលរដ្ឋ កាត់បន្ថយភាពអត់ការងារធ្វើ និងភាពចំណាកស្រុករបស់ពលរដ្ឋ ។

៤- អភិវឌ្ឍវិស័យសេដ្ឋកិច្ច ,

-ចាត់វិធានការអោយរដ្ឋអនុវត្តន៏រដ្ឋធម្មនុញ្ញ ,នីតិរដ្ឋ,

-ចាត់វិធានការមិនអោយរូបបិយប័ណ្ណបរទេសធ្វើចរន្តលើមាតុភូមិកម្ពុជា រាល់ការចំណាយត្រូវប្តូរជារូបបិយប័ណ្ណកម្ពុជា និងប្រើប្រាស់រូបបិយប័ណ្ណកម្ពុជាប៉ុណ្ណោះ ។ គឺ ជំរុញអោយពលរដ្ឋយល់ច្បាស់អំពីប្រយោជន៏ នៃការបង់ពន្ធជូនរដ្ឋ រដ្ឋអាចអភិវឌ្ឍន៏ប្រទេសបានអាស្រ័យលើការបង់ពន្ធជូនរដ្ឋ ពន្ធដែលទទួលបានពីការបង់ពន្ធរបស់ពលរដ្ឋ ត្រូវបញ្ជាក់ច្បាស់ជូនពលរដ្ឋជ្រាប ។

-ថវិការប្រមូលពន្ធបានប៉ុន្មានក្នុង១ខែ ?

-រដ្ឋនាំយកទៅប្រើប្រាស់អ្វីខ្លះ ?

-ប្រយោជន៏បានទៅលើអ្នកណា ?

គណបក្សខ្មែរអភិវឌ្ឍន៏សេដ្ឋកិច្ច មានគោលការណ៏ជាក់លាក់សំរាប់អភិវឌ្ឍន៏សេដ្ឋកិច្ចកម្ពុជា។

ក- តំឡើងប្រាក់បៀវត្ស មន្រ្តីរាជការ យុទ្ធជន បុគ្គលិក ចាប់ពី១,០០០,០០០.០០រៀល "មួយលានរៀល " ឡើងទៅ។

ខ- តំឡើងប្រាក់ពលកម្មប្រចាំថ្ងៃថ្នាក់កម្មករ ២៨,០០០.០០រៀលក្នុង១ថ្ងៃ ឡើងទៅ ក្នុងនោះបើគិតជាប្រាក់ខែដោយកាត់ថ្ងៃអាទិត្យចេញ គឺ ៧២៨,០០០រៀល គិតជាដុល្លា បច្ចុប្បន្ន គឺ១៨០ដុល្លាក្នុង១ខែ សំរាប់កម្មករកាត់ដេរ។

គ- ចាត់កំណត់ប្រេងសាំង ម៉ាស៊ូត អោយមានតម្លៃស្មើរប្រទេសថៃ និងម៉ាឡេស៊ី

ឃ- មិនអនុញ្ញាតិអោយចល័ត ឬផ្លាស់ប្តូរមន្រ្តីរាជការ ទាំងតួរនាទី ទាំងមុខងារ ចាំបាច់ត្រូវរក្សាតំណែង និងជំរុញអោយមន្រ្តីរាជការអនុវត្តន៏រដ្ឋធម្មនុញ្ញ ដែលជាសច្ចានុម័តរបស់សភាជាតិ។ តុលាត្រូវការកាត់ទោសអ្នកដែលសម្លាប់ខ្មែរពិត ព្រោះខ្មែរមិនមែនជាអ្នកសម្លាប់ខ្មែរទេ ។

- ចាត់សាងសង់អាគារស្នាក់នៅរបស់មន្រ្តីរាជការ បុគ្គលិកក្រសួងមន្ទីរ ទាហ៊ាន ប៉ូលីស គោលបំណងកាត់បន្ថយ រាល់ការចំណាយ ប្រេងធ្វើដំណើរ ចំណាយការស្នាក់នៅ ចំណាយពេលវេលារកក្តីស្រឡាញ់ក្រៅផ្ទះ ដែលជាជំងឺសង្គម នាំភាពក្តៅក្រហាយដល់កូនប្រពន្ធ ។ល។

- សាងសង់សាលារៀន មន្ទីរពេទ្យ អារាមសាសនា និង ផ្លូវគមនាគមន៏ ដែលជាសម្បត្តិសាធារណ: ក្រោមព្រះរាជកិច្ចព្រះករុណាព្រះមហាក្សត្រ ការរៀបចំ សាងសង់សាលារៀន មន្ទីរពេទ្យ អារាមសាសនា និង ផ្លូវគមនាគមន៏ ដែលជាសម្បត្តិសាធារណ: គឺជាភារ:កិច្ចរបស់រាជរដ្ឋាភិបាល ការប្រោសប្រ

ទាន  គឺជាព្រះរាជកិច្ចរបស់ព្រះករុណាជាម្ចាស់ព្រះមហាក្សត្រ ដែលរដ្ឋាភិបាលចំបាច់ត្រូវរៀបចំថ្វាយព្រះករុណា ជាព្រះរាជកិច្ច ព្រោះទាំងនេះជាសម្បត្តិជាតិ និង ជាសម្បត្តិព្រះមហាក្សត្រ ។

= តើ **គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច** បានប្រាក់ពីណាមកអភិវឌ្ឍសេដ្ឋកិច្ច  និងបើកប្រាក់បៀវត្សមន្ត្រីរាជការ បញ្ចុះតម្លៃប្រេង   សាងសង់សាលារៀន មន្ទីរពេទ្យ និង ផ្លូវគមនាគមន៍ ។ល។ ?

**បញ្ជាក់ជូនជាក់លាក់** ,

- បើតាមការពិនិត្យ និងស្រាវជ្រាវ របស់អ្នកសេដ្ឋកិច្ចឃើញថា រូបបីយប័ណ្ណបរទេសបាននិងកំពុងធ្វើចរន្ត លើមាតុភូមិកម្ពុជា  ប្រមាណ១00,000,000,000.00ដុល្លា "ដប់ម៉ឺនលានដុល្លាអាមេរិក" ការដែលកំណត់ប្រមាណនេះ ដោយសំអាងទៅលើសេចក្តីប្រកាសរបស់រដ្ឋាភិបាល  សំរាប់ខ្ទង់ចំណាយឆ្នាំ២0១៣  និងកញ្ចប់ថវិការចំណូលមកវិញជាង ៣,000.00លាន និង ការអភិវឌ្ឍន៏កម្ពុជា  ទើបមានស្ថិតិសង្ខេប ប្រមាណជាង ១00,000,000,000.00ដុល្លានេះ ធ្វើចរន្តលើកម្ពុជា។

យើងគ្រាន់តែលើកយកអត្រាប្តូរប្រាក់ទិញនិងលក់ ដុល្លា គឺ ១ដុល្លាចំណូលបាន ៣00រៀល គុណ និងដប់ម៉ឺនលានដុល្លា ស្មើរ ៣0,000,000,000,000.00រៀល សំរាប់ ១ឆ្នាំ ។ បើយើងនាំយកមកបើកប្រាក់បៀវត្ស មន្ត្រីរាជការ ១ខែ ស្មើរ  ២,៥00,000,000,000.00រៀល  នេះគឺជាទឹកប្រាក់ដែល **គណបក្សខ្មែរអភិវឌ្ឍន៏សេដ្ឋកិច្ច**   ចាំបាច់នាំមកបើកប្រាក់បៀវត្សជូនមន្ត្រីរាជការទាំងអស់ចាប់ពី ១,000,000.00រៀលឡើងទៅនេះ។

- ថវិការដែលនាំមកសាងសង់អាគារស្នាក់នៅរបស់មន្ត្រីរាជការ សាលារៀន មន្ទីរពេទ្យ ។ល។

- គឺបានមកពីការប្រមូលពន្ធរបស់រដ្ឋ ។

១-   ពន្ធនាំចូល ច្រក ភ្នំពេញ កំពង់សោម កំពត តាកែវ ស្វាយរៀង ព្រៃវែង កំពង់ចាមឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង កោះកុង និង កណ្តាល  ។ល។  ពន្ធនាំចូលមានអត្រា១0%ឡើងទៅ ។

២-ពន្ធអាករចល័ត ១0% នៃតម្លៃទំនិញ ចរន្ត ។

= នេះគឺជាកញ្ចប់ថវិការសំរាប់ការសាងសង់ និងអភិវឌ្ឍន៏កម្ពុជាទៅតាមគោលការណ៏របស់ គណបក្សខ្មែរអភិវឌ្ឍន៏សេដ្ឋកិច្ច។

-ការបញ្ចុះតម្លៃប្រេង គឺរដ្ឋាភិបាលចាំបាច់ត្រូវធ្វើការទិញលក់ប្រេងជាមួយក្រុមហ៊ុនបរទេសដោយកំណត់តម្លៃជាវិជ្ជមាន និងលក់អោយក្រុមហ៊ុនឯកជនវិញ  ដោយកំណត់អោយលក់តាមតម្លៃដែលរដ្ឋបានកំណត់ជាផ្លូវការ ពលរដ្ឋទទួលប្រយោជន៏ រដ្ឋទទួលបានពន្ធ នាំយកមកអភិវឌ្ឍកម្ពុជា ។

## គោលនយោបាយ  គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច

**សូមគោរព  បងប្អូនជនរួមជាតិជាទីគោរពស្នេហា សូមគោរពសម្តេច  ឯកឧត្តម អ្នកឧកញ៉ា  លោកជំទាវ  លោក  លោកស្រី  បងប្អូនទាំងអស់ជាទីគោរព**

ជាង២0ឆ្នាំហើយដែលកម្ពុជារួចផុតពីសំណាញ់ឈ្លានពាននៃសង្គ្រាមលទ្ធិ  កម្ពុជាបានទទួលសេរីភាពក្នុងការជ្រើសរើសអ្នកដឹកនាំដែលប្រកបដោយសេរី បែបប្រជាធិបតេយ្យ  ក្រោមព្រះរាជកិច្ចព្រះករុណាជាម្ចាស់ព្រះមហាក្សត្រកម្ពុជា ។

បងប្អូនជនរួមជាតិជាទីគោរពស្នេហា នៅថ្ងៃទី ២៨ ខែកក្កដាឆ្នាំ២0១៣ គឺជាថ្ងៃសិទ្ធិសេរីភាពរបស់បងប្អូនជនរួមជាតិទាំងអស់  សំរាប់ការជ្រើសរើស អ្នកដឹកនាំដែលមានគុណធម៌ និងព្រហ្មវិហាធម៌ សំរាប់ការពារជាតិ មាតុភូមិ ការពារបងប្អូនជនរួមជាតិ។  ជាង២0ឆ្នាំនេះ  រាជរដ្ឋាភិបាលបានអភិវឌ្ឍន៏កម្ពុជាជាជុំហ៊ាន១    ប៉ុន្តែបងប្អូនប្រជាពលរដ្ឋទទួលបានភាពចំណាកស្រុករាប់មិនអស់  ការធ្វើចំណាកស្រុកគឺជាការព្រាត់ប្រាស់និរាស ប្រពន្ធព្រាត់ប្តី កូនព្រាត់ឪពុកម្តាយ ជីដូនព្រាត់ចៅ ការព្រាត់ប្រាស់និរាស គឺមូលហេតុមកពីកម្ពុជាមិនមានសេដ្ឋកិច្ច ប្រជាពលរដ្ឋមិនមានការងារធ្វើ មិនមានសុវត្ថិភាពសង្គម ។

នៅនីតិកាលទី៥នេះ  ដើម្បីការពារសិទ្ធិពលរដ្ឋ ការពារនិតិរដ្ឋ ការពារសេដ្ឋកិច្ចជាតិ និង អភិវឌ្ឍន៏មាតុភូមិ គណបក្សខ្មែរអភិវឌ្ឍន៏សេដ្ឋកិច្ច មានកិត្តិយស សូមចូលខ្លួនមកបំរើបងប្អូនជនរួមជាតិទាំងអស់  ក្នុងទំព័រនយោបាយ មកឈរឈ្មោះបោះឆ្នោតនៅ សម័យនីតិកាលទី៥នេះ ។

គណបក្សខ្មែរអភិវឌ្ឍន៏សេដ្ឋកិច្ច  បានទទួលការចុះបញ្ជីឈរឈ្មោះបោះឆ្នោតបានចំនួន ៧ ខេត្តក្រុងប៉ុណ្ណោះ  ដូចនេះវាសនា  គណបក្សខ្មែរអភិវឌ្ឍន៏សេដ្ឋកិច្ច  ស្ថិតនៅក្នុងដៃរបស់បងប្អូនជនរួមជាតិជាទីគោរពស្នេហាហើយ។

គណបក្សខ្មែរអភិវឌ្ឍន៏សេដ្ឋកិច្ច មានគោលនយោបាយ អភិវឌ្ឍន៏ ៤ធំ តាមលំនាំព្រះករុណាព្រះមហាវិរៈក្សត្រខ្មែរ។

១-អភិឌ្ឍន៏វិស័យធនធានមនុស្ស

២-អភិឌ្ឍន៏វិស័យកសិឧស្សាហកម្ម

៣-អភិវឌ្ឍន៏វិស័យទេសចរណ៏

៤-អភិវឌ្ឍន៏កសាងវិស័យសេដ្ឋកិច្ចជាតិ

\+  ជំរុញអោយមានការអនុវត្តន៏ :

## តើ គណៈបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច មានន័យដូចម្តេច ?

**គណបក្ស** = ការរួបរួមគ្នា ជាក្រុម ជាបក្ស , ខ្មែរ + ការអភិវឌ្ឍន៍ = សេដ្ឋកិច្ច

- រូបទំពាំងខ្ពស់ជាងដើមឫស្សី មានន័យថា : យុវវ័យបច្ចុប្បន្ន ស្នងមនុស្សជំនាន់មុន
- ឫស្សី ៥ដើម បញ្ជាក់ថា យុវវ័យបច្ចុប្បន្នជំនាន់អង្គរធំ មុនសម័យអង្គរ គឺ: សញ្ញាប្រាសាទកំពូល ៥
- ទំពាំង៥ដើម គឺ: ប្រាទកំពូល៥ ក្នុងសាសនាព្រះ៥អង្គរ ក្នុងអណាគតិទី៥ ឈរលើលេខរៀងទី៥

**បាវចនា : សច្ចៈ សុចរិត យុត្តិធម** និង **សង្គ្រោះ បំរើ ការពារ**

សច្ចៈ - រាល់សេចក្តីសំរេច សេចក្តីប្រកាស ត្រូវទទួលខុសត្រូវ និងអនុវត្តន៍ជាចាំបាច់ ។

សុចរិត - ធ្វើអ្វីគ្រប់យ៉ាងដោយភាពត្រឹមត្រូវ មិនប្រកាន់បក្សពួក មិត្តភ័ក្រ បងប្អូន អនុវត្តន៍និតិរដ្ឋ ។

យុត្តិធមិ - ផ្តល់យុត្តិធមិស្មើរគ្នា មិនមាន អ្នកធំ មិនមាន អ្នកតូច មិនមានអ្នកមាន មិនមានអ្នកក្រ ។

សង្គ្រោះ - ជួយពលរដ្ឋដែលកំពុងរងទុក សុំអោយរដ្ឋាភិបាលជួយ ។

បំរើ - រកការងារផ្តល់ជូនពលរដ្ឋ និង ពន្យល់បង្ហាញ អោយពលរដ្ឋយល់ និងធ្វើការបាន ។

ការពារ - ចាត់មន្ត្រីពិនិត្យរាល់ការងារពលរដ្ឋ មិនអោយជនឈ្លាតឱកាសកេងប្រវ័ញ្ចប្រជាជន ។

**<u>គោលនយោបាយបក្ស</u>**

១- អភិវឌ្ឍន៍ធនធានមនុស្ស

២- អភិវឌ្ឍន៍កសិឧស្សាហកម្ម

៣- អភិវឌ្ឍន៍ទេសចរណ៍

៤- អភិវឌ្ឍន៍សេដ្ឋកិច្ច

បងប្អូនជនរួមជាតិជាទីគោរព អ្វីទាំងអស់នេះ គឺជាគោលការណ៍របស់ **គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច** គោលនយោបាយនេះអាចអភិវឌ្ឍន៍បាន គឺមានតែរដ្ឋាភិបាលប៉ុណ្ណោះ បើបងប្អូនចង់អោយរដ្ឋាភិបាលអនុវត្តន៍គោលនយោបាយ នេះ លុះត្រាតែអោយ **គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច** ក្លាយទៅជារដ្ឋាភិបាល។

ដើម្បីអោយ **គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច** ទៅជារដ្ឋាភិបាល លុះត្រាតែបងប្អូនជនរួមជាតិទាំងអស់បោះឆ្នោតអោយ ទើបក្លាយទៅជារដ្ឋាភិបាល។

**មានន័យថា បើចង់ប្រើខ្មែរអភិវឌ្ឍសេដ្ឋកិច្ច បោះឆ្នោតអោយទៅបាទ ។**

- តើបងប្អូនជនរួមជាតិអោយកូនចៅរៀនសូត្រ ដើម្បីអ្វី ? ជាទាសករ ឬជាទំពាំងស្នងឫស្សី ?
- តើមន្ត្រីរាជការទាំងអស់ចង់បានប្រាក់បៀវត្ស ចាប់ពី ១,000,000.00រៀល ឡើងទៅដែរឬទេ ?
- តើមន្ត្រីរាជការទាំងអស់ ចង់បានអាគារស្នាក់នៅ កាត់បន្ថយការចំណាយដែរឬទេ ?
- តើប្រជាពលរដ្ឋទាំងអស់ចង់បានប្រាក់ពលកម្ម ចាប់ពី ២៨,000.00រៀល ឡើងទៅក្នុង១ថ្ងៃដែរឬទេ ?
- តើចង់បានប្រេងតាមតម្លៃប្រទេសថៃនិងមាឡេស៊ីដែរឬទេ ?

ទាំងអស់នេះគឺស្ថិតនៅក្នុងដៃបងប្អូនជនរួមជាតិជាទីគោរពស្នេហាទាំងអស់ នៅថ្ងៃទី ២៨ ខែកក្កដា ២០១៣ នេះ ។

**លក់ឈ្មោះ លក់សិទ្ធិ គិតខុស រងគ្រោះ៥ឆ្នាំ ទើបមានម្តង ។**

គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច

ប្រធាន

**ហួន រាជចំរើន**

## គណៈបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច

**លក់ឈ្មោះ លក់សិទ្ធិ គិតខុស រងគ្រោះ៥ឆ្នាំ ទើបមានម្តង**

**តើយកប្រាក់លើកទឹកចិត្ត ២០០,០០០.០០រៀល**

**ឬយកការងារធ្វើ ?**

**គោលនយោបាយ អភិវឌ្ឍន៍ ធំ ៤**

១-អភិវឌ្ឍន៍ធុនធានមនុស្ស

២-អភិវឌ្ឍន៍កសិឧស្សាហកម្ម

៣-អភិវឌ្ឍន៍ទេសចរណ៍

៤- អភិវឌ្ឍន៍សេដ្ឋកិច្ច